ព័ត៌មានជាតិ

# ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ និងអង្គការហ្វារពន្លឺសិល្បៈ បានដាក់តាំងពិព័រណ៍សិល្បៈបាត់ដំបងក្នុងក្តីស្រមៃ រយៈពេល៥ថ្ងៃនៅក្រុងបាត់ដំបង

២៣-តុលា-២០២៣ ០៣:៣២ ល្ងាច 372 Share



បាត់ដំបង ៖ ពិព័រណ៍សិល្បៈ ក្រោមប្រធានបទ បាត់ដំបងក្នុងក្តីស្រមៃ ត្រូវបានបើកដាក់ឱ្យដំណើរការ រយៈពេល៥ថ្ងៃ នៅក្រុងបាត់ដំបង ខេត្តបាត់ដំបង ក្រោមការរៀបចំឡើងដោយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ AFD និងអង្គការហ្វារពន្លឺសិល្បៈខេត្តបាត់ដំបង ចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៣ នៅសួនច្បារសម្តេចក្រឡាហោម ស ខេង ក្រុងបាត់ដំបង ខេត្តបាត់ដំបង ។

កម្មវិធីបាត់ដំបងក្នុងក្តីស្រមៃ ដែលធ្វើការដាក់តាំងបង្ហាញពីស្នាដៃតាមរយៈការស្រមើស្រមៃរបស់សិល្បករចំនួន២៧រូបនៃសមាគមហ្វារពន្លឺសិល្បៈ អំពីសក្តានុពលនៅក្នុងខេត្តបាត់ដំបង ព្រមជាមួយនឹងការសម្តែងសៀកដ៏គួរឱ្យចាប់អារម្មណ៍ ដែលជាផ្នែកមួយនៃការរំលឹកខួប៣០ឆ្នាំរបស់អង្គការហ្វាពន្លឺសិល្បៈដែលប្រកបដោយវឌ្ឍនភាព ។

លោក ឃួន ដេត សហស្ថាបនិក និងជានាយកសាលាសិល្បៈទស្សនីយភាព នៃសមាគមហ្វារពន្លឺសិល្បៈ ក្នុងពិធីបើកការតាំងពិព័រណ៍បាត់ដំបង

ក្នុងក្តីស្រមៃ បានបញ្ជាក់ថា គោលបំណងនៃការតាំងពិព័រណ៍នៅទីនេះ គឺមិនមែនក្តីស្រមៃទៅអនាគតត្រឹមតែជាទ្រឹស្តីនោះទេ ប៉ុន្តែវាពិតជាអាចក្លាយជាការពិតនៅក្នុងឆ្នាំ២០៣០នាពេលដ៏ខ្លីខាងមុខ ប្រសិនបើយើងអនុវត្តជាប្រចាំតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ។

ទេពកោសល្យដ៏កម្រនិងភាពច្នៃប្រឌិតនៃសិល្បករ សិល្បការិនីរបស់យើង ធ្វើឱ្យយើងទទួលបាននូវអនាគត ដែលយើងប្រាថ្នាចង់បាន ដោយការប្តេជ្ញាចិត្តអនុវត្តជាក់ស្តែងនៅថ្ងៃនេះដើម្បីថ្ងៃស្អែក ។ ការដាក់តាំងពិព័រណ៍នូវស្នាដៃរបស់សិល្បករ សិល្បការិនី បានបង្ហាញពីថាមពលនៃការអប់រំនិងទេពកោសល្យដ៏កម្ររបស់ពួកគេរៀងៗខ្លួន ពួកគេរង់ចាំការរីកដុះដាលទៅកាន់សង្គមដ៏ភ្លឺស្វាងមួយនេះ ហើយពួកគេគូសវាសផ្លូវនិងបង្ហាញយើងថា អនាគតគឺអាចចាប់ផ្តើមនៅថ្ងៃនេះ ។

លោក ឃួន ច័ន្ទរស្មី នាយកគម្រោងនៃសមាគមហ្វាពន្លឺសិល្បៈ បានបញ្ជាក់យ៉ាងដូច្នេះថា គោលបំណងនៃការរៀបចំពិព័រណ៍សិល្បៈនាពេលនេះ គឺដើម្បីបង្ហាញនូវសក្ខីកម្មមួយយ៉ាងល្អ សម្រាប់បង្ហាញអំពីកិច្ចសហប្រតិបត្តិការ ក៏ដូចគ្នានឹងការបង្ហាញអំពីកង្វល់របស់សិល្បករ សិល្បការិនីថា គាត់មានគំនិតយ៉ាងណាសម្រាប់អនាគតនៃទីក្រុង និងអនាគតនៃទីកន្លែងរបស់គាត់ក្នុងពេល១៥ឆ្នាំឬ២០ឆ្នាំទៅខាងមុខ ជាពិសេសនៅក្នុងឆ្នាំ២០៣០ គឺគាត់ចង់ឃើញពីភាពវិវឌ្ឍន៍រីកចម្រើននៅតំបន់បាក់ព្រានៃស្រុកឯកភ្នំ និងការបញ្ឈប់បានទាំងស្រុងនូវការនេសាទដែលបំផ្លាញមច្ឆជាតិ មកជាការនេសាទតាមបែបអភិរក្សមច្ឆជាតិ ។

អភិបាលខេត្តបាត់ដំបង លោក សុខ លូ បានបង្ហាញនូវការគាំទ្រយ៉ាងសំខាន់ដែលហ្វាពន្លឺសិល្បៈ បានយកចិត្តទុកដាក់ក្នុងការបង្កើតឲ្យមានកម្មវិធីសិល្បៈផ្សេងៗជាលក្ខណៈអប់រំដល់ប្រជាពលរដ្ឋ ដែលទាំងអស់នេះបានជួយលើកស្ទួយនូវកំណើនភ្ញៀវទេសចរណ៍ឲ្យមកលេងកម្សាន្តនៅក្នុងប្រទេសកម្ពុជា ជាពិសេសខេត្តបាត់ដំបងផ្ទាល់តែម្តង ដែលជាកត្តាចូលរួមចំណែកយ៉ាងធំធេងនៅក្នុងការនាំភ្ញៀវទេសចរមកកាន់ខេត្តបាត់ដំបង ដើម្បីបង្កើននូវសេដ្ឋកិច្ចជាតិ កាន់តែមានការរីកចម្រើន ៕

ដោយ៖ គួយ គឹមស៊ន














OiEau


















AFD



